សន្លឹកព័ត៌មានស្តីពីថ្នាំវ៉ាក់សាំង

# ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A៖
## *តើលោកអ្នកត្រូវដឹងអ្វីខ្លះ*

Many Vaccine Information Statements are available in Khmer and other languages. See www.immunize.org/vis

សេចក្តីថ្លែងការណ៍នៃព័ត៌មានអំពីថ្នាំវ៉ាក់សាំងជាច្រើនគឺអាចរកបានជាភាសាខ្មែរ និងភាសាផ្សេងទៀត។ ចូលមើល www.immunize.org/vis

## 1. ហេតុអ្វីត្រូវចាក់ថ្នាំវ៉ាក់សាំង?

**ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A** អាចបង្ការ **ជំងឺរលាកថ្លើមប្រភេទ A បាន**។

**ជំងឺរលាកថ្លើមប្រភេទ A** គឺជាជំងឺថ្លើមធ្ងន់ធ្ងរមួយ។ ជាធម្មតាវាំរីករាលដាលតាមរយៈទំនាក់ទំនងជិតស្និទ្ធ ផ្ទាល់ខ្លួនជាមួយអ្នក ដែលមានមេរោគ ឬនៅពេលដែលមនុស្សម្នាក់បានឆ្លងមេរោគដោយ មិនដឹង ខ្លួនពីវត្ថុ អាហារ ឬភេសជ្ជៈដែលកខ្វក់ដោយលាមក (អាចម៍) តិចតួចពីផ្ទុក ជំងឺ។

មនុស្សពេញវ័យភាគច្រើនដែលមានជំងឺរលាកថ្លើមប្រភេទ A មានរោគសញ្ញា រួមមាន អស់កម្លាំង ចំណង់អាហារទាប ឈឺក្រពះ ចង្អោរ និងខាន់លឿង (ស្បែក ឬភ្នែកលឿង ទឹកនោមល្អក់ ចលនាពោះវៀនស្រាល)។ ភាគច្រើននៃកុមារមានអាយុក្រោម 6 ឆ្នាំ មិនមានរោគសញ្ញាទាំងនេះទេ។

អ្នកដែលឆ្លងជំងឺរលាកថ្លើមប្រភេទ A អាចចម្លងជំងឺនេះទៅមនុស្សផ្សេង ទៀត ទោះបីជាគាត់មិនមានរោគសញ្ញានៃជំងឺក៏ដោយ។

មនុស្សភាគច្រើនដែលមានជំងឺរលាកថ្លើមប្រភេទ A មានអារម្មណ៍ឈឺអស់ រយៈពេលជាច្រើនសប្តាហ៍ ប៉ុន្តែជាធម្មតាពួកគេអាចជាសះស្បើយទាំងស្រុង ហើយមិនខូចថ្លើមយូរអង្វែងនោះទេ។ ក្នុងករណីកម្រ ជំងឺរលាកថ្លើមប្រភេទ A អាចបណ្តាលឱ្យខ្សោយថ្លើម និងស្លាប់។ ករណីនេះច្រើនកើតមានចំពោះមនុស្សដែលមានអាយុលើសពី 50 ឆ្នាំ និងចំពោះអ្នក ដែលមានជំងឺថ្លើមផ្សេងទៀត។

វ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A បានធ្វើឱ្យជំងឺនេះមិនសូវកើតមាននៅក្នុង សហរដ្ឋអាមេរិក។ ទោះយ៉ាងណាក៏ដោយ ការផ្ទុះឡើងនៃជំងឺរលាកថ្លើមប្រភេទ A ក្នុងចំណោមអ្នកដែលមិនបានទទួលថ្នាំបង្ការនៅតែកើតមានឡើង។

## 2. ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A

**កុមារ** តម្រូវឱ្យទទួលវ៉ាក់សាំងរលាកថ្លើម A 2 ដូស៖
- ដូសទីមួយ៖ អាយុចាប់ពី 12 ខែដល់ 23 ខែ
- ដូសទីពីរ៖ យ៉ាងតិចណាស់ 6 ខែ បន្ទាប់ពីទទួលវ៉ាក់សាំងលើកទីមួយ

**ទារកមានអាយុចាប់ពី 6 ខែ ដល់ 11 ខែ** ធ្វើ ដំណើរចេញក្រៅសហរដ្ឋអាមេរិកនៅពេលដែលណែនាំឱ្យការពារពីជំងឺរលាកថ្លើម A ត្រូវទទួលវ៉ាក់សាំងរលាកថ្លើម A ដូសទី 1។ កុមារទាំងនេះគួរតែទទួលបាន 2 ដូសនៅអាយុដែលបានណែនាំសម្រាប់ការការពារយូរអង្វែង។

**កុមារធំ និងក្មេងជំទង់** ចាប់ពីអាយុ 2 ដល់ 18 ឆ្នាំ ដែលមិនទាន់បានចាក់វ៉ាក់សាំងពីមុន គួរ ចាក់វ៉ាក់សាំង។

**មនុស្សពេញវ័យ** ដែលពុំបានចាក់ថ្នាំវ៉ាក់សាំងពីមុន ហើយចង់បង្ការជំងឺរលាកថ្លើមប្រភេទ A ក៏អាចទទួលថ្នាំវ៉ាក់សាំងនេះបានផងដែរ។

វ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A ក៏ត្រូវបានណែនាំសម្រាប់មនុស្សដូចខាងក្រោម៖
- អ្នកដំណើរអន្តរជាតិ
- បុរសដែលរួមភេទជាមួយបុរសដទៃទៀត
- អ្នកដែលប្រើថ្នាំញៀនចាក់ ឬមិនចាក់ថ្នាំ
- មនុស្សដែលមានហានិភ័យការងារសម្រាប់ការឆ្លងមេរោគ
- មនុស្សដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកសុំកូនចិញ្ចឹមអន្តរជាតិ
- មនុស្សដែលជួបប្រទះនឹងភាពគ្មានផ្ទះសម្បែង
- អ្នកផ្ទុកមេរោគអេដស៍
- អ្នកមានជំងឺថ្លើមរ៉ាំរ៉ៃ។

លើសពីនេះ អ្នកដែលមិនទាន់បានទទួលវ៉ាក់សាំងការពារជំងឺរលាកថ្លើម ប្រភេទ A ពីមុនមក ហើយអ្នកដែលមានទំនាក់ទំនងផ្ទាល់ជាមួយអ្នក ដែលមានជំងឺរលាកថ្លើម ប្រភេទ A គួរតែទទួលបានវ៉ាក់សាំងការពារជំងឺ រលាកថ្លើមប្រភេទ A ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងក្នុងរយៈពេល 2 សប្តាហ៍បន្ទាប់ពីការប៉ះពាល់។

ថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A អាចចាក់នៅពេលដំណាលគ្នានឹងថ្នាំវ៉ាក់សាំងដទៃទៀត។

U.S. Department of Health and Human Services
Centers for Disease Control and Prevention

## 3. និយាយជាមួយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នក ដើម្បីស្វែងយល់បន្ថែមទៀត។

ប្រាប់អ្នកផ្តល់វ៉ាក់សាំងរបស់អ្នក ប្រសិនបើបុគ្គលនោះទទួលវ៉ាក់សាំង៖

- មាន **ប្រតិកម្មអាឡែហ្ស៊ី បន្ទាប់ពី ការចាក់ វ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A ពីមុន**ឬមាន**អាឡែស៊ីធ្ងន់ធ្ងរ និងគំរាមកំហែងដល់អាយុជីវិត**

ក្នុងករណីខ្លះ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកអាចសម្រេច ចិត្តពន្យារពេលការចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ A រហូតដល់ ការមកជួបនាពេលខាងមុខ។

ស្ត្រីមានផ្ទៃពោះ ឬបំបៅដោះកូនគួរតែចាក់វ៉ាក់សាំង ប្រសិនបើពួកគេ មានហានិភ័យក្នុងការកើតជំងឺរលាកថ្លើមប្រភេទ A។ ការមានផ្ទៃពោះ ឬការបំបៅដោះកូនមិនមែនជាហេតុផលដើម្បីចៀសវាងការចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ A នោះទេ។

អ្នកដែលមានជំងឺស្រាល ដូចជាជំងឺផ្តាសាយ អាចទទួលថ្នាំបង្ការនេះបាន។ អ្នកដែលមានជំងឺធ្ងន់ល្មម ឬធ្ងន់ធ្ងរ គួររង់ចាំ រហូតដល់ពួកគេជាសះស្បើយសិន មុនពេលទទួលថ្នាំវ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ A។

អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នកអាចផ្តល់ព័ត៌មានបន្ថែមដល់លោកអ្នកបាន។

## 4. ហានិភ័យកើតប្រតិកម្មថ្នាំវ៉ាក់សាំង

- អាការៈឈឺ ឬឡើងក្រហមនៅកន្លែងចាក់ថ្នាំ ក្តៅខ្លួន ឈឺក្បាល អស់កម្លាំង ឬបាត់បង់ចំណង់អាហារអាចកើតឡើងបន្ទាប់ពីចាក់វ៉ាក់សាំងការពារជំងឺរលាកថ្លើមប្រភេទ A។

ពេលខ្លះ មនុស្សសន្លប់ បន្ទាប់ពីដំណើរការវេជ្ជសាស្ត្ររួមទាំងការចាក់ថ្នាំវ៉ាក់សាំង។ សូមប្រាប់អ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក ប្រសិនបើលោកអ្នកវិលមុខ ឬចក្ខុញ្ញាណផ្លាស់ប្តូរ ឬឮសំឡេងហឹងក្នុងត្រចៀក។

ដូចថ្នាំផ្សេងទៀតដែរ ថ្នាំវ៉ាក់សាំងកម្រនឹងបង្កប្រតិកម្មអាលែហ្ស៊ីធ្ងន់ធ្ងរ របួសធ្ងន់ធ្ងរផ្សេង ឬធ្វើឲ្យស្លាប់បាត់បង់ជីវិតណាស់។

## 5. ចុះបើមានបញ្ហាធ្ងន់ធ្ងរ?

ប្រតិកម្មអាលែហ្ស៊ីអាចកើតឡើងបន្ទាប់ពីអ្នកទទួលថ្នាំបង្ការចាកចេញពីគ្លីនិក។ ប្រសិនបើអ្នកឃើញសញ្ញានៃប្រតិកម្មធ្ងន់ធ្ងរ (កន្ទួលកហម ហើមមុខ និងបំពង់ក ពិបាកដកដង្ហើម បេះដូងលោតញាប់ វិលមុខ ឬខ្សោយ) សូមទូរស័ព្ទទៅ **9-1-1** ហើយនាំមនុស្សទៅមន្ទីរពេទ្យដែលនៅជិតបំផុត។ សម្រាប់សញ្ញាផ្សេងទៀតដែលធ្វើឱ្យអ្នកបារម្ភសូមទូរស័ព្ទទៅអ្នកផ្តល់សេវាថែទាំ សុខភាពរបស់អ្នក។

ប្រតិកម្មទៅប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំងគួរតែត្រូវបានរាយការណ៍ទៅ Vaccine Adverse Event Reporting System (VAERS)។ អ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកជាធម្មតានឹងដាក់របាយការណ៍នេះ ឬអ្នកអាចធ្វើវាដោយខ្លួនឯងបាន។ សូមចូលទៅគេហទំព័រប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង [www.vaers.hhs.gov](http://www.vaers.hhs.gov) ឬទូរស័ព្ទទៅលេខ **1-800-822-7967**។ *ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (VAERS) សម្រាប់តែការរាយការណ៍ប្រតិកម្មប៉ុណ្ណោះ។ សមាជិកបុគ្គលិករបស់ប្រព័ន្ធរាយការណ៍ផលអាក្រក់នៃថ្នាំវ៉ាក់សាំង (VAERS) មិនផ្តល់ដំបូន្មានផ្នែកវេជ្ជសាស្ត្រទេ។*

## 6. កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង

National Vaccine Injury Compensation Program (កម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង (VICP)) គឺជាកម្មវិធីរបស់រដ្ឋសហព័ន្ធ ដែលបានបង្កើតឡើងដើម្បីបង់សងអ្នកទាំងឡាយដែលអាចរងរបួសដោយសារតែថ្នាំវ៉ាក់សាំងមួយចំនួន។ ការទាមទារទាក់ទងនឹងរបួស ឬការស្លាប់ដោយសារការទទួលថ្នាំបង្ការ មានពេលវេលាកំណត់សម្រាប់ការដាក់ឯកសារ ដែលអាចមានរយៈពេលខ្លី ត្រឹមពីរឆ្នាំ។ សូមចូលមើលគេហទំព័រកម្មវិធីជាតិបង់សំណងរបួសដោយសារថ្នាំវ៉ាក់សាំង [www.hrsa.gov/vaccinecompensation](http://www.hrsa.gov/vaccinecompensation) ឬហៅទូរសព្ទទៅលេខ **1-800-338-2382** ដើម្បីសិក្សាអំពីកម្មវិធី និងការដាក់ពាក្យទាមទារ។

## 7. តើខ្ញុំអាចសិក្សាបន្ថែមទៀតដោយរបៀបណា?

- សូមសួរអ្នកផ្តល់សេវាថែទាំសុខភាពរបស់លោកអ្នក។
- សូមទូរស័ព្ទទៅក្រសួងសុខាភិបាលរដ្ឋ ឬនៅមូលដ្ឋានរបស់លោកអ្នក។
- សូមចូលទៅ Food and Drug Administration (គេហទំព័ររដ្ឋបាលអាហារនិងឱសថ (FDA)) ដម្បីទទួលបានកញ្ចប់សេវាកម្មថ្នាំបង្ការ និងព័ត៌មានបន្ថែម [www.fda.gov/vaccines-blood-biologics/vaccines](http://www.fda.gov/vaccines-blood-biologics/vaccines)។
- Centers for Disease Control and Prevention (សូមទាក់ទងមជ្ឈមណ្ឌលទប់ស្កាត់ និងបង្ការជំងឺ (CDC))៖
  - សូមទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)** ឬ
  - ចូលមើលគេហទំព័ររបស់ CDC នៅ [www.cdc.gov/vaccines](http://www.cdc.gov/vaccines)។

Khmer translation provided by Immunize.org